សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា អំពីធម៌សំរាប់ធ្វើជាមេដឹកនាំគេ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ

ថ្ងៃទី១ កញ្ញា ២០០៤

ប្រភេទនៃធម៌ដែលសំរាប់ធ្វើជាមេគេ ឬជានាយកលើគេ មានជាច្រើនយ៉ាង តែក្នុងពេលនេះសូមអធិប្បាយចំពោះធម៌ដែលសំរាប់ការរស់នៅក្នុងក្រុមឬសង្គមមួយ ឲ្យមានការឈ្លាសវៃនិងប៉ិនប្រសប់ក្នុងការដឹកនាំ ដើម្បីសេចក្តីសុខចំរើន ដល់អ្នកដែលនៅក្រោមបង្គាប់ ។ ធម៌នោះមាននិយាយនៅក្នុងសុត្តន្តបិដកផ្នែកព្រះសូត្រ ដែលមានមតិកា៦យ៉ាងគឺ ៖

១- **ខមា** ៖ ប្រែថាមានសេចក្តីអត់ធ្មត់ គឺធ្វើជានាយកលើគេ ត្រូវមានសេចក្តីអត់ធន់ចំពោះការលំបាកគ្រប់យ៉ាង តាមផ្លូវកាយនិងផ្លូវចិត្ត ជាពិសេសចំពោះការរិះគន់ពីអ្នកដទៃ ពុំមានការក្រេវក្រោធ រហូតមានគំនិតព្យាបាទចំពោះអ្នករិះគន់ដើម្បីស្តាបនានោះឡើយ ។

២- **ជាគរិយៈ** ៖ ប្រែថាមានសេចក្តីភ្ញាក់រលឹករឿយៗ គឺធ្វើជានាយកលើគេ ត្រូវមានការឈ្លាសវៃ មានស្មារតីរស់រវើកជានិច្ច មានគំនិតផ្តួចផ្តើមបង្កើតផែនការ រិះរកមធ្យោបាយធ្វើយ៉ាងណា ឲ្យក្រុមឬសង្គមរបស់ខ្លួនបានលូតលាស់ចំរើន គឺមិនស្តាប់គំនិតដូចមនុស្សដេកលក់ ត្រូវដឹងមុខងារនាទីរបស់ខ្លួន ថាថ្ងៃនេះត្រូវធ្វើអ្វី ហើយថ្ងៃស្អែកត្រូវធ្វើអ្វីទៀតជាដើម។ បើអ្នកអ្នកដឹកនាំជាតិក៏ដូចគ្នា ត្រូវមានស្មារតីរស់រវើកនិងឈ្លាសវៃបំផុត ក្នុងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ។ បើមានជម្លោះផ្ទៃក្នុង ត្រូវដោះស្រាយដោយសន្តិវិធី ឲ្យមានឯកភាពជាតិជៀសវាងការជ្រៀតជ្រែកពីខាងក្រៅ ។

៣- **ឧដ្ឋានៈ** ៖ ប្រែថាមានសេចក្តីឧស្សាហ៍ព្យាយាម គឺធ្វើជានាយកដឹកនាំ ត្រូវមានសេចក្តីព្យាយាមយ៉ាងខ្លាំងក្លា ឲ្យជាគំរូដល់អ្នកដទៃទៀត ជាពិសេសឲ្យជាគំរូដល់សហការីរបស់ខ្លួន ។

៤- **សំវិភាគៈ** ៖ ប្រែថាការចែករំលែក អ្នកធ្វើជាមេដឹកត្រូវចេះចែករំលែកគ្រឿងចិញ្ចឹមជីវិត ដូចជាប្រដាប់ប្រដាប្រើប្រាស់ ចំណីអាហារបរិភោគជាដើម ដល់អ្នកធ្វើការជាមួយ ឲ្យសមរម្យល្មមរស់នៅបានផង ។ មួយទៀតត្រូវចាត់ចែងការងារឲ្យសមាជិកធ្វើ ឲ្យស្របទៅតាមកម្លាំងកាយនិងកម្លាំងសមត្ថភាព ។ បើនិយាយពីក្រុមហ៊ុនវិញ ត្រូវផ្តល់ប្រាក់ខែឲ្យកម្មករឲ្យបានសមរម្យ បើបានចំណេញច្រើន ត្រូវតម្លើងប្រាក់បៀវត្សបន្ថែមទៀតដល់កម្មករ ។ ត្រូវចេះលើកទឹកចិត្តកម្មករ ដោយផ្តល់ប្រាក់បំណាច់ឲ្យកម្មករម្តងម្កាល ។ ត្រង់ន័យនេះ គួរឲ្យអាណិតអាសូរដល់កម្មករខ្មែរនៅប្រទេសកម្ពុជាបច្ចុប្បន្ននេះ ត្រូវមេក្រុមហ៊ុនខ្លះប្រមាថមើលងាយ បង្ខំឲ្យធ្វើការលើសម៉ោង គ្មានផ្តល់ប្រាក់បន្ថែមឲ្យសមរម្យ ។ កម្មករបានស្នើសុំឲ្យលក្ខខណ្ឌការងារបានល្អជាងមុន សុំដំឡើងប្រាក់ខែ ក៏មេក្រុមហ៊ុននិងអាជ្ញាធរខ្មែរគ្មានយកចិត្តទុកដាក់ យកសំណើរបស់កម្មករទៅដោះស្រាយឡើយ ។ ដោយអត់ទ្រាំនឹងការរំលោភលើសិទ្ធិរបស់ខ្លួនដែលជាកម្មករលែងបានទៀត ក៏ធ្វើកូដកម្មដើម្បីបង្ខំឲ្យមេក្រុមហ៊ុនដោះស្រាយ តែលទ្ធផលនៅតែសូន្យ ថែមទាំងអាជ្ញាធរដែលឃុបឃិតជាមួយក្រុមហ៊ុន បញ្ជូនប៉ូលិសនិងកងអាវុធហត្ថមកវាយធ្វើបាបកម្មករថែមទៀត ។

៥- **ទយា** ៖ ប្រែថាមានចិត្តអាណិតអាសូរ គឺនាយកដឹកនាំឬមេក្រុមហ៊ុនមានចិត្តអាណិតអាសូរដល់សហការីឬកម្មករដែលធ្វើការ ឲ្យដូចឪពុកម្តាយស្រឡាញ់កូន ។ បើកម្មករមានជម្ងឺ ត្រូវឲ្យសំរាក ហើយបញ្ជូនទៅមន្ទីរពេទ្យ កុំប្រើទាំងឈឺ ។ បើកម្មករមានវិបត្តិផ្លូវចិត្ត ត្រូវជួយណែនាំនិយាយពន្យល់ហេតុផល ឲ្យមានកម្លាំងចិត្តឡើងវិញ ។

៦- **ឥក្ខនា** ៖ ប្រែថាការពិនិត្យមើលកិច្ចការដែលបានធ្វើ ដើម្បីកែលំអឲ្យបានប្រសើរឡើងទៀត ។ ការបានចំរើនលូតលាស់នៃសង្គមមួយ ឬក្រុមហ៊ុនមួយ ពុំមែនត្រឹមតែផែនការដែលដាក់ចេញឲ្យអនុវត្តប៉ុណ្ណោះទេ គឺនៅលើអ្នកអនុវត្តដែលជាសមាជិក ឬកម្មករពេញចិត្តអនុវត្តផង ។ ដើម្បីឲ្យសមាជិឬកម្មករធ្វើសហការដោយការរីករាយផង លុះត្រាតែមានលក្ខខណ្ឌការងារបានល្អ ពុំរំលោភលើសិទ្ធិសមាជិកឬកម្មករ ។ កាលណាសមាជិកឬកម្មករធ្វើសហការដោយពេញចិត្ត និងដោយសារតែខ្លួនបានទទួលកម្រៃបន្ថែម នៅពេលដែលលទ្ធផលនៃការងារបានលូតលាស់ ទើបក្រុមហ៊ុនជាដើមនោះកាន់តែមានវឌ្ឍនភាពនិងមានស្ថេរភាព ។ បញ្ហាជាតិក៏ដូចគ្នា លុះត្រាតែប្រជាពលរដ្ឋធ្វើសហការជាមួយរដ្ឋាភិបាលទើបធ្វើឲ្យប្រទេសមានសន្តិភាព វឌ្ឍនភាព និងស្ថេរភាព ។

នាយកធម៌ទាំង៦នេះ ជាធម៌សំរាប់ការដឹកនាំតូចធំ ទាំងផ្នែកសង្គមកិច្ចវប្បធម៌ ទាំងផ្នែកនយោបាយ ត្រូវអនុវត្ត ។ ចំណែកទសពិធរាជធម៌១០យ៉ាងនោះ សំរាប់ការដឹកនាំនយោបាយជាន់ខ្ពស់ ។

មានមេដឹកនាំខ្មែរនៃគណបក្សមួយបានពោលអួតក្អេងក្អាងថា ចិនកុម្មុយនិស្តបាននិយាយថា ខ្មែរមានអ្នកដឹកនាំសំខាន់តែបីនាក់ទេ ។ ក្នុងចំណោមបីនាក់នោះ គឺខ្លួនអ្នកប្រាប់អ្នកសារពត៌មាននោះម្នាក់ដែរ ។ ចិនកុម្មុយនិស្តត្រូវពិភពលោកចោទថា រំលោភសិទ្ធិមនុស្ស បិទសិទ្ធិការបញ្ចេញយោបល់ ពុំមានសារពត៌មានឯកជន ពុំមានគណបក្សនយោបាយប្រណាំងប្រជែង គឺមានគណបក្សតែមួយ គឺគណបក្សកុម្មុយនិស្ត ។ ត្រង់ចិនកាន់លទ្ធិអ្វី ជាកិច្ចការផ្ទៃក្នុងរបស់ចិនទេ ។ ប៉ុន្តែត្រង់ធ្វើឲ្យខ្មែរចាប់អារម្មណ៍នោះ គឺចិនបានគាំទ្រខ្មែរក្រហម ផ្តល់គ្រាប់បែកគ្រាប់កាំភ្លើងឲ្យសម្លាប់ខ្មែរអស់ជិតបីលាននាក់ ។ គឺដោយសារស្នាដៃចិនកុម្មុយនិស្តនៅពីក្រោយខ្មែរក្រហម បានធ្វើឲ្យប្រជាពលរដ្ឋខ្មែរនៃប្រទេសកម្ពុជា រងទុក្ខវេទនារហូតមកទល់សព្វថ្ងៃនេះ ។ ចិនកុម្មុយនិស្តពុំដែលសរសើរលើកដំកើងអ្នកប្រជាធិបតេយ្យឡើយ មានតែពោលសរសើរអ្នកផ្តាច់ការដូចគ្នា គឺនិស្ស័យត្រូវគ្នាវារត់រកគ្នា ព្រោះប្រេងនឹងទឹកពុំអាចរលាយចូលគ្នាឡើយ ។ មេគណបក្សនោះបានពោលទៀតថា បានជារួមចូលធ្វើរដ្ឋាភិបាលជាមួយគណបក្សមួយទៀត តាមរយៈការបោះឆ្នោតជាកញ្ចប់នោះ មកអំពីកុំឲ្យមានការបង្ហូរឈាមគ្នា ។ បើពុំព្រមរួមធ្វើរដ្ឋាភិបាលជាមួយគ្នាក្នុងពេលនេះទេ នឹងបង្ហូរឈាមគ្នាខ្លាំងជាងឆ្នាំ១៩៩៧ទៅទៀត ។ ត្រង់នេះគ្រាន់តែជាការដោះសារ ដើម្បីបិទបាំងអំពើឆ្កាំឆ្កង ដែលបានប្រព្រឹត្តរំលោភច្បាប់រដ្ឋធម្មនុញ្ញ ដែលមានជាធរមានរបស់ជាតិប៉ុណ្ណោះ ។ បើការគំរាមកំហែងបែបណាមួយពិតជាមានទៅចុះ ហើយបើដឹងថាធ្វើការជាមួយគ្នាពីរអាណត្តិ ហើយពុំបានស៊ីសង្វាក់គ្នា ពុំអាចឲ្យជាតិដើរទៅមុខក្នុងវឌ្ឍនភាពទេ ហេតុអ្វីក៏នៅតែចូលរួម ? ការចូលរួមដោយការខ្លាចរហូតសុខចិត្តរំលោភច្បាប់កំពូលរបស់ជាតិ រំលោភលទ្ធិប្រជាធិបតេយ្យដោយបោះឆ្នោតលើកដៃនេះ ជាភស្តុតាងបញ្ជាក់ថា គណបក្សនេះទន់ខ្សោយ គ្មានជំហររឹងប៉ឹងខ្លួនឯង ធ្វើតាមការគំរាមកំហែង ដោយបោះបង់គោ

លជំហរខ្លួនឯង ថែមទាំងបោះបង់សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ ដែលជាមិត្តភក្តិរបស់ខ្លួនពីមុន និងបង្កើតសត្រូវដល់គ្នានិងគ្នាថែមទៀត ហើយលូកដៃទៅឱបគណបក្សមួយទៀត ដែលខ្លួនចាត់ទុកជាសត្រូវរបស់សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ ។ ដូចនេះគណបក្សមួយទៀត ដែលយើងចោទគេថាជាសត្រូវនោះ គេនឹកអស់សំណើចក្នុងចិត្ត ជាមួយនឹងបំណងរបស់គេបានសំរេចហើយ គឺបំបែកសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យក្លែងក្លាយនេះឲ្យបែកគ្នាហើយ ដោយស៊ីនុយដែលគេបានដាក់ដើម្បីឲ្យបែកគ្នា ។ ដូច្នេះការរួមគ្នានេះ ពុំមែនដោយហេតុការណ៍គំរាមកំហែងទេ គឺដោយហេតុការណ៍ចែកលាភសក្ការៈគ្នារវាងគណបក្សទាំងពីរ សូម្បីលាភសក្ការៈខ្លះបន្តិចបន្តួច ក៏មិនព្រមឲ្យគណបក្សមួយទៀតនៅក្នុងសភាផង ។ គួរពិចារណាខ្លួនដោយខ្លួនឯង គណបក្សមួយនោះកាលពីឆ្នាំ១៩៩៣ មានសម្លេងគ្រាន់បើ ឆ្នាំ១៩៩៨ សម្លេងគាំទ្រចុះ ឆ្នាំ២០០៣ រឹតតែចុះទៅទៀត តើឆ្នាំ២០០៨ ទៅជាយ៉ាងណា ចុះឬឡើង ប្រជាពលរដ្ឋខ្មែរនឹងវិនិច្ឆ័យសកម្មភាពរបស់គណបក្សមួយនេះក្នុងអាណត្តិទី៤ខាងមុខនេះ ។ បើហេតុការណ៍កើតឡើងថា បើពុំធ្វើតាមគេទេនឹងកើតការបង្ហូរឈាមគ្នា គួរទុកឲ្យការបង្ហូរឈាមគ្នាមួយពេល ជាជាងទុកឲ្យប្រជាពលរដ្ឋរងទុក្ខវេទនាវែងឆ្ងាយតទៅទៀត បើនៅតែធ្វើតាម តើហេតុការណ៍នេះមានប៉ុន្មានដងទៅមុខទៀត ដែលតែងតែកើតឡើងរាល់ពេលបោះឆ្នោតរួច ។ យើងពុំយកចិត្តទុកដាក់ ត្រង់គណបក្សណាមួយត្រូវរលាយឬពុំរលាយនៅពេលខាងមុខនេះទេ ប៉ុន្តែយើងអាណិតចំពោះប្រជាពលរដ្ឋខ្មែរ ដែលទទួលរងទុក្ខវេទនា ដោយជឿគណបក្សណាមួយហើយនាំគេដើរផ្លូវខុស ។

មានគណបក្សមួយទៀត សុខចិត្តគាំទ្រប្រទេសភូមា ដែលពិភពលោកចោទថា ជាប្រទេសកាន់លទ្ធិផ្តាច់ការ ឲ្យចូលទៅប្រជុំប្រទេសអឺរ៉ុបអាស៊ី ។ បើគ្រាន់តែគាំទ្រប៉ុណ្ណោះមិនជាខ្លាំងប៉ុន្មានទេ ដែលខ្លាំងបំផុតនោះ គឺត្រង់ពោលថា បើមិនឲ្យប្រទេសភូមាទៅប្រជុំទេ ប្រទេសកម្ពុជានឹងធ្វើពហិការមិនចូលទៅប្រជុំដែរ ។ អស្ចារ្យណាស់ ស្មោះត្រង់នឹងមិត្តភក្តិរហូតហ៊ានលះបង់ប្រយោជន៍ជាតិខ្លួន ។ និស្ស័យវាសនាដូចគ្នា វាត្រូវតែរត់រកគ្នាយ៉ាងនេះឯង ។ រដ្ឋាភិបាលសុខចិត្តឲ្យតំណាងអង្គការសហប្រជាជាតិខាងអ្នកភៀសខ្លួន ទៅយកអ្នកព្រៃភ្នំវៀតណាម មិនបញ្ជូនទៅវៀតណាមវិញ ដោយសារមានការគាបសង្កត់ ។ ដូច្នេះរដ្ឋាភិបាលគ្មានសម្បជញ្ញៈខ្លួនឯងទេ ដល់តែមានការគាបសង្កត់ ទើបកែប្រែចិត្តគំនិត ដោយសារតែយកចិត្តប្រទេសវៀតណាម ដែលធ្លាប់មានគុណដល់គណបក្សនេះតាំងពីដើមមក ។ មួយទៀត រដ្ឋាភិបាលអនុញ្ញាតឲ្យជនជាតិវៀតណាមចំនួន១៩ខេត្តនៅប្រទេសកម្ពុជាបើកសមាគម ប៉ុន្តែពុំបានពិនិត្យថា តើជនជាតិវៀតណាមទាំងនោះ មកកម្ពុជាស្របច្បាប់ ឬពុំស្របច្បាប់ទេ ។ ផ្ទុយទៅវិញ ជនរួមជាតិខ្មែរនៅកម្ពុជាក្រោម ដែលរងទុក្ខវេទនានៅលើទឹកដីកំណើតរបស់ខ្លួន ដោយសារវៀតណាមធ្វើបាប រដ្ឋាភិបាលខ្មែរស្ងាត់ច្រៀប គ្មានធ្វើអន្តរាគមន៍ជួយកុំឲ្យវៀតណាមធ្វើបាបខ្មែរក្រោម ឬសុំរដ្ឋាភិបាលវៀតណាម ឲ្យខ្មែរក្រោមបង្កើតសមាគម ដើម្បីការពារសិទ្ធិខ្មែរជាជនជាតិភាគតិចដូចនៅកម្ពុជាផងទេ ដោយគេពុំបានអនុវត្តតាមរដ្ឋធម្មនុញ្ញខ្មែរ ត្រង់មាត្រា៣៣ដែលចែងថា ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។៚